**SUPERINTENDENT OF PUBLIC INSTRUCTION**

*Randy I. Dorn* Old Capitol Building · PO BOX 47200 · Olympia, WA 98504-7200 · http://www.k12.wa.us

## តើអ្វីទៅជាការវាយតម្លៃជំនាញផ្នែកភាសាអង់គ្លេសនៅទីក្រុងវ៉ាស៊ិនតោន?

ការវាយតម្លៃជំនាញផ្នែកភាសាអង់គ្លេសនៅទីក្រុងវ៉ាស៊ិនតោន(វ៉ែលភា) គឺជាការប្រលងដែលត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលប្រសិនបើសិស្ស និស្សិតត្រូវការការគាំទ្រតាមរយៈកម្មវិធីអភិវឌ្ឍន៍ភាសាអង់គ្លេសថ្នាក់ស្រុក(វ៉ែឌ)។ការវាយតម្លៃនេះ ប្រលងទៅលើចំណេះដឹងនិងជំនាញលើការអានការសរសេរការស្តាប់និងការនិយាយភាសាអង់គ្លេស។ កូនសិស្សនៅសាលាមត្តេយ្យដល់ថ្នាក់ទី១២ត្រូវធ្វើការប្រលងនេះមួយឆ្នាំម្តងៗ ដើម្បីស្ទង់មើលកំរិតនៃការលូតលាស់ក្នុងការសិក្សារភាសារអង់គ្លេសនៅក្នុងសាលារៀន។ ដោយហេតុថាការដឹងនិងការប្រើប្រាស់ភាសាអង់គ្លេសបានល្អ គឺជាការសំខាន់សម្រាប់ភាពជោគជ័យក្នុងសាលារៀន វាគឺជាការចាំបាច់ដែលកូនសិស្សណាដែលត្រូវការជំនួយបន្ថែមក្នុងការសិក្សារភាសាអង់គ្លេស ទទួលបានការជំនួយដែលពួកគេត្រូវការ។

## តើសិស្សមានគុណសម្បត្តិចូលរៀនក្នុងកមµវិធីអភិវឌ្ឍនភាសាអង់គ្លេសរបៀបណា?

នៅពេលយកកូនទៅចុះឈµោះចូលរៀន, នោះឪពុកម្តាយនឹងត្រូវគេសួរថា “តើកូនរបស់លោកអ្នកចេះនិយាយភាសាដំបូងរបស់គេក្រៅពីភាសាអង់គ្លេសឬ?” បើចម្លើយឆ្លើយថា “បាទឬចា៎ះ”, នោះកូនរបស់លោកអ្នកត្រូវធ្វើតេស្ត Washington English Language Proficiency Assessment (WELPA) Placement Test។ បណ្តាសិស្សដែលទទួលបានពិន្ទុ Level 1 (ចាប់ផ្តើម), Level 2 (មធ្យម), ឬ Level 3 (ខ្ពស់) លើតេស្តចំណាត់ថ្នាក់ (Placement Test) របស់ពួកគេ នឹងមានគុណសម្បត្តិទទួលជំនួយបន្ថែម ដើម្បីបង្កើនជំនាញភាសាអង់គ្លេសរបស់ពួកគេ។

## តើសិស្សអាចទទួលជំនួយតាមរយៈកមµវិធីអភិវឌ្ឍនភាសាអង់គ្លេសរបស់មណ្ឌលសិក្សាធិការបានយូរប៉ុណ្ណា?

ដរាបណាសិស្សនៅតែត្រូវការជំនួយរៀនភាសាអង់គ្លេស, នោះពួកគេអាចបន្តក្នុងកមµវិធីនេះរហូតទាល់តែពួកចេះ។ ការធ្វើតេស្ត WELPA ប្រចាំឆ្នាំគឺដើម្បីវាស់ស្ទង់ការរីកចម្រើន និងជំនាញក្នុងការអាន, ការសរសេរ, ការស្តាប់, និងការនិយាយ។ ពិន្ទុLevels 1, 2, ឬ3 លើតេស្ត WELPA កំណត់ថា សិស្សនឹងបន្តក្នុងកមµវិធីនេះ។ សិស្សនឹងចាកចេញពីកមµវិធីនេះដោយជោគជ័យ នៅពេលណាពួកគេបានបំពេញតាមលក្ខណវិនិច្ឆ័យនៃតេស្ត WELPA។